**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ ២១១ រប-៩៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ឆ្នាំ**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការសុំផ្លាស់ប្តូរអ្នកការពារក្តី របស់ជនជាប់ចោទឈ្មោះ.............។

ខ្ញុំសូមជម្រាបលោកប្រធានជ្រាបថា តាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ២១ ក្រ ចុះថ្ងៃទី០៨-០៣-៩៣ ពុំមានមាត្រាណាមួយហាមឃាត់ថា មិនអោយជនជាប់ចោទផ្លាស់ប្តូរអ្នកការពារឡើយ ។ ជនជាប់ចោទមានសិទ្ធិបរិបូណ៌ក្នុងការសុំផ្លាស់ប្តូរអ្នកការពារប្តីរបស់ខ្លួនបាន ។ ហើយបញ្ហានេះទៀតសោតក៏បានលើកយកមកពិភាក្សាក្នុងអង្គសន្និបាតបំណាច់ឆ្នាំ១៩៩៥ ថ្មីៗនេះ ដែរ ។ អាស្រ័យហេតុនេះសូមលោកប្រធានអនុញ្ញាតឱ្យជនជាប់ចោទឈ្មោះ...បានផ្លាស់ប្តូរអ្នកការពារក្តីដូចពាក្យស្នើសុំ ចុះថ្ងៃទី០៥-០១-៩៦ ទៅតុលាការរួចហើយនោះ តាមការគួរតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

ចម្លងជូន

- -សមាគមអាជហុក
- -តុលាការគ្រប់ខេត្ត-ក្រុង
- -តុលាការយោធា
- -សាលាឧទ្ធរណ៍
- -តុលាការកំពូល